**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលកិច្ចប្រជុំឧត្តមមន្ត្រីអាស៊ាន-នូវ៉ែលហ្សេឡង់ លើកទី ២៧
# ថ្ងៃទី២០-២១ ខែកុម្ភៈ ឆ្នាំ២០២០ នៅខេត្តសៀមរាប

កិច្ចប្រជុំឧត្តមមន្ត្រីអាស៊ាន-នូវ៉ែលហ្សេឡង់ លើកទី២៧ បានប្រព្រឹត្តទៅនៅថ្ងៃទី២០-២១ ខែកុម្ភៈ ឆ្នាំ២០២០ នៅខេត្តសៀមរាប ប្រទេសកម្ពុជា។ ក្នុងនាមជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-នូវ៉ែលហ្សេឡង់ កម្ពុជាបានធ្វើជាម្ចាស់ផ្ទះ និងជាធ្វើសហប្រធាននៃកិច្ចប្រជុំជាមួយប្រទេសនូវ៉ែលហ្សេឡង់។ កិច្ចប្រជុំនេះផ្តល់នូវកាលានុវត្តសម្រាប់អាស៊ាន និងប្រទេសនូវ៉ែលហ្សេឡង់ ដើម្បីពិនិត្យឡើងវិញនូវកិច្ចសហប្រតិបត្តិការ និងរៀបចំទិសដៅនាពេលអនាគត និងដើម្បីត្រៀមរៀបចំកិច្ចប្រជុំកំពូលថ្នាក់នាំអាស៊ាន-នូវ៉ែលហ្សេឡង់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ នៅទីក្រុងដាណាង ប្រទេសវៀតណាម។

នៅក្នុងសុន្ទរកថាបើកក្នុងនាមសហប្រធាននៃកិច្ចប្រជុំ **ឯកឧត្តម កាន់ ផាវិទ្ធ** រដ្ឋលេខាធិការ និងជាឧត្តមមន្ត្រីអាស៊ាន-កម្ពុជា បានបញ្ជាក់ជាថ្មីម្តងទៀតនូវការប្តេជ្ញាចិត្តឥតងាករេរបស់អាស៊ាន ចំពោះភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-នូវ៉ែលហ្សេឡង់ ដែលបានផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។ **ឯកឧត្តម** បានសម្តែងនូវការពេញចិត្តយ៉ាងខ្លាំង ចំពោះវឌ្ឍនភាពជាក់ស្តែងដែលសម្រេចបានក្នុងការអនុវត្តផែនការសកម្មភាពអាស៊ាន-នូវ៉ែលហ្សេឡង់ឆ្នាំ ២០១៦-២០២០ ដែលមានសកម្មភាពទាំងអស់ចំនួន ៥៩ ត្រូវបានអនុវត្ត។ **ឯកឧត្តម** បានបញ្ជាក់ថាកម្ពុជានឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយបណ្តាប្រទេសសមាជិកអាស៊ាន និងប្រទេសនូវ៉ែលហ្សេឡង់ដើម្បីរួមគ្នាដោះស្រាយនូវបញ្ហាប្រឈមរួម និងដើម្បីកសាងសមិទ្ធផលឱ្យទទួលជោគជ័យជាមួយគ្នាបន្ថែមទៀតនាពេលអនាគត ក្នុងបំណងថែទាំសន្តិភាព ស្ថិរភាព និងលើកស្ទួយវិបុលភាព ក្នុងតំបន់។

**ឯកឧត្តម បេនចាមីន ឃីង** (Benjamin King) លេខាធិការរង ទទួលបន្ទុកទ្វីបអាមេរិក និងទ្វីបអាស៊ី នៃក្រសួងការបរទេស និងពាណិជ្ជកម្មនូវ៉ែលហ្សេឡង់ ជាសហប្រធាននៃកិច្ចប្រជុំ បានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរបស់នូវ៉ែលហ្សេឡង់ ក្នុងការលើកកម្ពស់ទំនាក់ទំនងអាស៊ាន-នូវ៉ែលហ្សេឡង់បន្ថែមទៀត។ ឯកឧត្តមបានបញ្ជាក់ពីការគាំទ្ររបស់នូវ៉ែលហ្សេឡង់ដល់វិជ្ជមានភាពអាស៊ាននៃដំណើរការវិវឌ្ឍន៍



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

និម្មាបនកម្មតំបន់ ដើម្បីថែទាំសន្តិភាព ស្ថិរភាព និងលើកស្ទួយវិបុលភាព ក្នុងតំបន់។ ទន្ទឹមនឹងនេះ ឯកឧត្តមក៏មានសុទិដ្ឋិនិយមដូចកម្ពុជាដែរថា ភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-នូវ៉ែលហ្សេឡង់នឹងឈានដល់កម្រិតថ្មីមួយ ខណៈពេលដែលនូវ៉ែលហ្សេឡង់បានធ្វើការយ៉ាងជិតស្និទ្ធជាមួយអាស៊ានដើម្បីបញ្ចប់ផែនការសកម្មភាពថ្មី (២០២១-២០២៥) លើវិស័យជាក់ស្តែងថ្មីៗនៃកិច្ចសហប្រតិបត្តិការដែលឆ្លុះបញ្ចាំងនូវកិច្ចសហប្រតិបត្តិការស៊ីជម្រៅជាមួយអាស៊ានលើសសរស្តម្ភទាំង៣។ ឯកឧត្តម ក៏បានបញ្ជាក់ថា នូវ៉ែលហ្សេឡង់ទន្ទឹងរង់ចាំការរៀបចំប្រកបដោយជោគជ័យនៃកិច្ចប្រជុំកំពូលថ្នាក់នាំអាស៊ាន-នូវ៉ែលហ្សេឡង់នាពេលខាងមុខ នៅទីក្រុងដាណាង ក្រោមការសម្របសម្រួលរបស់កម្ពុជា។

អង្គប្រជុំបានពិភាក្សាអំពីបញ្ហាជាច្រើនដែលជាផលប្រយោជន៍ និងជាកង្វល់រួម។ ប្រធានបទដែលកិច្ចប្រជុំបានពិភាក្សា ជាអាទិ៍រួមមាន៖ ការវិវត្តថ្មីៗនៅក្នុងអាស៊ាន នៅក្នុងប្រទេសនូវ៉ែលហ្សេឡង់ និងនៅតំបន់ប៉ាស៊ីហ្វិកខាងត្បូង ព្រមទាំងបញ្ហាក្នុងតំបន់ និងអន្តរជាតិ ដូចជា ទស្សនទានឥណ្ឌូ-ប៉ាស៊ីហ្វិក ឧបទ្វីបកូរ៉េ បញ្ហាជ្រុលនិយម និងឧក្រិដ្ឋកម្មឆ្លងដែន និងការប្រែប្រួលអាកាសធាតុ ជាដើម។ អង្គប្រជុំក៏បានពិនិត្យឡើងវិញផងដែរនូវភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-នូវ៉ែលហ្សេឡង់ ដោយបានពិភាក្សាអំពីសកម្មភាពមួយចំនួនដែលអាចអនុវត្តរួមគ្នាដោយផ្តោតសំខាន់លើការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ការតភ្ជាប់ និងគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន។

អាស៊ាន និងនូវ៉ែលហ្សេឡង់បានពិភាក្សាលើឯកសារសំខាន់ចំនួនពីរ គឺ៖ ១. សេចក្តីព្រាងសេចក្តីប្រកាសទស្សនវិស័យរួមស្តីពីខួបអនុស្សាវរីយ៍លើកទី៤៥ឆ្នាំនៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-នូវ៉ែលហ្សេឡង់ក្រោមមូលបទ "កេរដំណែលមរតកមិត្តភាព និងអនាគតរួមគ្នា" ដែលនឹងត្រូវអនុម័តនៅក្នុងឱកាសកិច្ចប្រជុំកំពូលថ្នាក់ដឹកនាំអាស៊ាន-នូវ៉ែលហ្សេឡង់នាពេលខាងមុខ នៅទីក្រុងដាណាង ប្រទេសវៀតណាម និង ២. សេចក្តីព្រាងផែនការសកម្មភាពថ្មី (ឆ្នាំ២០២១-២០២៥) ដែលនឹងត្រូវអនុម័តនៅក្នុងឱកាសសន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានបូក១ជាមួយប្រទេសនូវ៉ែលហ្សេឡង់ដែលនឹងប្រព្រឹត្តទៅនៅខែសីហា ឆ្នាំ២០២០នេះ។ ឯកសារសំខាន់ទាំងពីរនេះផ្តល់ជាឯកសារគោលការណ៍ណែនាំ ដើម្បីតម្រង់ទិសវិស័យជាក់លាក់ថ្មីៗនៃកិច្ចសហប្រតិបត្តិការរវាងអាស៊ាន និងនូវ៉ែលហ្សេឡង់។

គណៈប្រតិភូអាស៊ាន និងនូវ៉ែលហ្សេឡង់ បានសម្តែងនូវការកោតសរសើរយ៉ាងខ្លាំងដល់កម្ពុជាចំពោះការធ្វើបដិសណ្ឋារកិច្ចដ៏កក់ក្តៅ និងការរៀបចំដ៏ល្អប្រសើរ រួមមានពិធីពិសារអាហារពេលល្ងាចជាមួយនឹងការសម្តែងសិល្បៈរបាំវប្បធម៌-ប្រពៃណីខ្មែរ៕

ថ្ងៃសុក្រ ១៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០